គណបក្ស សម រង្ស៊ី-សហរដ្ឋអាមេរិក

SAM RAINSY PARTY - UNITED STATES OF AMERICA

សីលធម៌ សច្ចធម៌ យុត្តិធម៌

គណបក្ស សម រង្ស៊ី
សាខាប្រចាំសហរដ្ឋអាមេរិក

Honorary President
*Mr. Dikhayuko Sen*

President
*Mr. Kim Ly Chea*

Vice President
*Mrs. Sophanny Bay*

Secretary General
*Mr. Tha Oum*
Deputy SG
*Mr. Tithia Sum*

Treasurer
*Mr. Mardi Seng*
Deputy Treasurer
*Mr. Synoun Kham*

Public Relations
*Mr. Marin Meas*

Membership
*Mr. Sakal Kim*

ID-Card Dept.
*Mr. Eng S. Neang*

Fundraising
*Mr. Tithia Sum, Chair*
*Mr. Cata Chiv*

Policy & Procedures
*Mr. Kovid Ho*

Litigation Council
*Mr. Vandy Sem, Chair*
*Dr. Yorn Meas,*
*Att. Sovantara Neang*
*Mr. Sreng Van*

Advisors
*Mr. Pheach Srey*
*Mr. Sovann Ou*
*Mr. Kunno Prai*
*Mrs. Raci Say*

# សេចក្តីអំពាវនាវជាបន្ទាន់

ការបោះឆ្នោតសាកលជាប្រវត្តិសាស្ត្រត្រូវចាប់ផ្តើមគឺនៅសល់តែ ១៣ ថ្ងៃទៀតទេ ។ សកម្មជន ព្រមទាំងថ្នាក់ដឹកនាំគណបក្សយើងទាំងអស់ត្រៀមធ្វើការសង្កេតមើលការរាប់សន្លឹកឆ្នោតរាល់ពេលវេលា គ្រប់មណ្ឌលបោះឆ្នោតទូទាំងប្រទេសរហូតដល់ចប់សព្វគ្រប់ជាស្ថាពរ ។

តាមបទពិសោធន៏នៃការបោះឆ្នោតពីរលើកកន្លងមក យើងឃើញថាគណបក្សកាន់អំណាចឈ្នះឆ្នោតដោយការប្រើល្បិចកល់ច្រើនយ៉ាងដូចជា៖
-បិតភ្លើងអគ្គីសនីពេលកំពុងរាប់សន្លឹកឆ្នោត ដើម្បីគេឆ្លៀតឱកាសបន្លំ ឬប្តូរហឹបឆ្នោត
-បង្កើតឲ្យមានព្រឹត្តិការណ៏ប្រទូស្តរាយនៅក្បែរកន្លែងរាប់សន្លឹកឆ្នោតដើម្បីបំភិតបំភ័យអ្នកសង្កេតការណ៏ដូចជាការបាញ់កាំភ្លើងបង្អើល និងការជួលមនុស្សពាលាឲ្យវាយតប់គ្នាបង្កើតចលាចល និងជាពិសេស
-នៅពេលដែលគ្មានអ្នកសង្កេតការណ៏នៅប្រចាំការជាក់ស្តែងដូចជានៅពេលអ្នកសង្កេតការណ៏អញ្ជើញទៅទទួលទានអាហារឆ្ងាយពីកន្លែងរាប់សន្លឹកឆ្នោតជាដើម ។ល។

ដើម្បីរៀបចំវិធានការណ៏ទប់ទល់កុំឲ្យបក្សកាន់អំណាចលួចបន្លំសន្លឹកឆ្នោតរបៀបនេះបានតទៅទៀត អនុគណកម្មការផ្តែកមូលនិធិគណកម្មការប្រតិបត្តិនៃគណបក្សសមរង្ស៊ីសាខាសហរដ្ឋអាមេរិក ព្រមទាំងរូបខ្ញុំផ្ទាល់ **សម រង្ស៊ី** សូមធ្វើ **សេចក្តីអំពាវនាវជាបន្ទាន់** ដល់សមានចិត្តជ្រះថ្លារបស់អស់លោក-លោកស្រី និងសមាជិក-ជិកនៃគណបក្ស សមរង្ស៊ីជាអ្នកស្រឡាញ់លិទ្ធិប្រជាធិបតេយ្យ ទាំងអស់ជាថ្មីម្តងទៀត សូមមេត្តាជួយធ្វើជាអ្នកឧបត្ថម្ភមណ្ឌលបោះឆ្នោតនិមួយៗដែលលោក-លោកស្រីអាចមានលទ្ធភាពជួយបាន ។

សូមជំរាបថាក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានមណ្ឌលបោះឆ្នោតទាំងអស់ចំនួន ១៣០០០កន្លែង ហើយមួយកន្លែងយើងត្រូវមានអ្នកសង្កេតការណ៏ពីររូបដែលត្រូវនៅប្រចាំការគ្រប់ពេលវេលាដើម្បីចាំសង្កេតមើលការរាប់សន្លឹកឆ្នោតរហូតទាល់តែចប់ត្រឹមត្រូវ ដូច្នេះក្នុងនេះ យើងត្រូវចំណាយថវិកាចំនួន $10 សំរាប់អ្នកសង្កេតការណ៏មួយមណ្ឌល ក្នុងមួយថ្ងៃ ។

ដោយហេតុដូចនេះ សូមអស់លោក-លោកស្រី ព្រមទាំងសមាជិក-ជិកាគណបក្សទាំងអស់ដែលស្រឡាញ់លទ្ធិប្រជាធិបតេយ្យ ហើយ ចង់ការពារសន្លឹកឆ្នោតដ៏មានតម្លៃរបស់ពលរដ្ឋយើងកុំឲ្យគេលួចបន្លំទៀត សូមមេត្តាជួយធ្វើជា **អ្នកឧបត្ថម្ភមណ្ឌលបោះឆ្នោត** ដោយជួយជាថវិកាសំរាប់ មួយមណ្ឌល ពីរមណ្ឌល ឬបីមណ្ឌល ទៅតាមលទ្ធភាពរបស់អស់លោក-លោកស្រីកុំបីខាន ។

សូមទាក់ទងមកថ្នាក់ដឹកនាំតាមរដ្ឋឬទីក្រុងនិមួយៗនៅក្បែរអស់លោក លោកស្រី បើអស់លោក លោកស្រីមានបំណងជួយធ្វើជា **អ្នកឧបត្ថម្ភមណ្ឌលបោះឆ្នោត** ។ សូមចូលរួមជាផ្នែកមួយនៃចលនាលិទ្ធប្រជាធិបតេយ្យតាមរយៈ **គណបក្ស សមរង្ស៊ី!!** ។

ធ្វើនៅ ថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០០៣

**ប្រធានគណបក្ស**

**សម រង្ស៊ី**

**ប្រធានអនុគណៈកម្មាធិការផ្នែកមូលនិធិនៃ គសរ-សរអា**

**ស៊ុំ ធិត្យា**

**Sam Rainsy Party -U.S.A.** PO BOX 2067, Lowell, MA 01851 – FAX (508) 643-7212